00345965

**Declassified to Public**
**06 September 2012**

E22/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 06 / 2009
ម៉ោង (Time/Heure) : 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. [signature]

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance
លេខ៖ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**
**សូមជំរាបជូន**
**លោកមេធាវី ការ សាវុត្ថ និង លោកមេធាវី François Roux**
**មេធាវីរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ**

**កម្មវត្ថុ÷** សំណើសុំចាត់តាំងអ្នកចិត្តវិទ្យាម្នាក់
**ចំណាត់ថ្នាក់ឯកសារ÷** សម្ងាត់បំផុត

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ លោកបានដាក់សំណើមួយទៅអង្គជំនុំជម្រះសាលាដំបូង ដោយលក្ខណៈសម្ងាត់បំផុត (Ex Parte)។ តាមរយៈខ្លឹមសារនៃសំណើនេះ លោកស្នើសុំឲ្យមានការចាត់តាំងអ្នកចិត្តវិទ្យាម្នាក់ដើម្បីជួយដល់កូនក្តីរបស់លោក នៅក្នុងពេលសវនាការពីដើមរហូតដល់ចប់ ជាអាទិ៍គឺដើម្បីឲ្យកូនក្តីរបស់លោកទទួលបានជំនួយមួយ ក្នុងករណីដែលមានការប្រឈមមុខទៅនឹងស្ថានភាពតានតឹងផ្នែកអារម្មណ៍។

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / 07 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

00345966

E22/3

តាមរយៈដីកាដែលមានលក្ខណៈសម្ងាត់បំផុតចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៨ អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងលោកសាស្ត្រាចារ្យ កា ស៊ុនបូណាត (KA Sunbaunat) ក្នុងនាមជាអ្នកជំនាញដែលមានភារៈចំបងដូចតទៅ៖

- *កំណត់ថាតើមានសញ្ញាណច្បាស់លាស់ដែលអាចបញ្ជាក់ថា ជនជាប់ចោទ "អាចប្រឈមមុខនឹងសភាពតានតឹងក្នុងអារម្មណ៍ដ៏ធ្ងន់ធ្ងរមួយដែលអាចបង្កឲ្យមានបញ្ហាលំបាកខ្លាំងលើផ្លូវចិត្តសាស្ត្រ បើសិនជាគាត់មិនបានទទួលនូវជំនួយដ៏ត្រឹមត្រូវពីអ្នកជំនាញដូចដែលក្រុមការពារក្តីបានអះអាង" ជាហេតុអាចបណ្តាលឲ្យគាត់គ្មានទីតិសម្បទាគ្រប់សម្រាប់ទទួលការជំនុំជម្រះនោះដែរឬទេ។*

- *និងបញ្ជាក់ពីកម្រិតនៃជំនួយផ្លូវចិត្តសាស្ត្រដែលត្រូវផ្តល់ឲ្យជនជាប់ចោទនៅក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី បើសិនជាតម្រូវឲ្យមានជំនួយចិត្តសាស្ត្រសម្រាប់គាត់។*

របាយការណ៍ផ្នែកជំនាញរបស់សាស្ត្រាចារ្យ Ka Sunbaunat ត្រូវបានដាក់ចូលក្នុងសំណុំរឿងកាលពីថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៨។ អ្នកជំនាញបានធ្វើសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍របស់ខ្លួនថា មកទល់នឹងពេលនេះជនជាប់ចោទមិនបានបង្ហាញនូវភាពតានតឹងផ្នែកអារម្មណ៍ដែលតម្រូវអោយមានជំនួយរបស់អ្នកចិត្តវិទ្យានៅក្នុងអំឡុងពេលជំនុំជម្រះនោះឡើយ។

អង្គជំនុំជម្រះសាលាដំបូងចង់ដឹងពីគោលជំហររបស់ក្រុមការពារក្តីចំពោះសេចក្តីសន្និដ្ឋានដែលបានបញ្ជាក់ខាងលើនេះ ឲ្យបានមុនថ្ងៃទី០៦ ខែកក្កដា ខាងមុខនេះ និងចង់ដឹងឲ្យបានលម្អិតជាងនេះទៅទៀតថាតើក្រុមការពារក្តីនៅតែមានបំណងរក្សាសំណើសុំឲ្យមានជំនួយចិត្តសាស្ត្រសម្រាប់កូនក្តីរបស់ខ្លួនដែរឬទេ។

ភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**